**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ ... ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ពរល.១១០៥.៤៩៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តមបណ្ឌិតសភាចារ្យ **តិច សំណាង** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី**។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៤៥៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

៣រ.ល. ១១០៥.៤៩៥

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

ឃុន ជិនកេន

នស/រកត/០៥១១/៤៩២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ

**ក-ដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ :**

- ឧត្តមសេនីយ៍ត្រី **ពេជ ពណ្ណរាយ** អត្តលេខ ០០១២០៦

**ខ-ដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមនាវីទោ :**

- ឧត្តមនាវីត្រី **ជឹម សុផល** អត្តលេខ ០០២៥២៣

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១១០៥.៤៩៦

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៤៧៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

នស/រកត/០៥១១/៤៩២

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ដល់ នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

**ក. ដំឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ :**

១- ឧត្តមសេនីយ៍ត្រី **យ៉ិនឡៀង ពុទ្ធិរិទ្ធ** អត្តលេខ ២៣១៧០២
២- ឧត្តមសេនីយ៍ត្រី **ដួង រ៉ា** អត្តលេខ ០០២៣២៩

**ខ. ដំឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី :**

១- វរសេនីយ៍ឯក **ឈួន យូ** អត្តលេខ ០៣៧១៨៧
២- វរសេនីយ៍ឯក **យ៉ិនឡៀង ពុទ្ធិរ៉ា** អត្តលេខ ២៣១៩៧៧
៣- វរសេនីយ៍ឯក **ឯម សារី** អត្តលេខ ០០៣៧៨៨

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.១១០៥.៤៩៧

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១*

លេខ ៤៩៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម **ឡេង សុគន្ធ** ជាទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៥.៤០០

*ធ្វើនៅព្រះបរមរាជវាំង ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១*

លេខ: ៥៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងលោកជំទាវ **ស៊ិន សារ៉ាឆន** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ ៤៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រល.១១០៥.៥០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

ឃុន ចិនាកន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

សប្បុរសជននិងនាយទាហាន ចំនួន០៨រូប បានជួយកសាងអភិវឌ្ឍន៍
ដល់កងពលតូចអន្តរាគមន៍លេខ ១៤ និង កសាងសមិទ្ធផលនានាក្នុងខេត្តព្រះវិហារ

**ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោក ZHANG YUN FENG
២- វរសេនីយ៍ឯក **កែវ ចាន់ថន** អត្តលេខ ០៣៧៦៤៤
៣- លោក LIU LE ZHONG
៤- លោក TIAN DI
៥- លោក ZHANG LING FENG

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១- ឧត្តមសេនីយ៍ត្រី **សុខ សាយ** អត្តលេខ ០០៨១៥៧
២- វរសេនីយ៍ឯក **ហ៊ុំ សាយ័ន្ត** អត្តលេខ ០០៨៥៥៨
៣- វរសេនីយ៍ត្រី **អ៊ុំ ណារ្រី** អត្តលេខ ០១២២៦៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ក.ស.ស. ១១០៥.៥០២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

លេខ: ៥៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤៩៨

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

សប្បុរសជននិងនាយទាហាន ចំនួន០៨រូប បានជួយកសាងនិងអភិវឌ្ឍន៍
ដល់កងពលតូចអន្តរាគមន៍លេខ ១៨ និងកសាងសមិទ្ធផលនានាក្នុងខេត្តព្រះវិហារ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

លោកជំទាវ **ទេព បុប្ផា ប្រសិទ្ធ**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- លោក **ជួន ទន**

២- លោក **សឺន សុជា**

៣- លោក **ផុក គីរីឫទ្ធិ**

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

ឧកញ៉ា **ហេង ឡុង**

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- ឯកឧត្តម **មាស សំណាង**

២- លោក **ទេព្យ ណារុង**

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

លោក **ហេង សុវណ្ណគីរី**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣រល.១១០៥.៥០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

**លេខ ៤៨០ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

សប្បុរសជន ចំនួន ០៤រូប ដែលបានជួយកសាងសមិទ្ធផលនានា
ក្នុងវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តកំពង់ស្ពឺ

**នូវ**

ក-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ព្រះតេជគុណ **សូរ ច័ន្ទ**

២-លោក **ជា សីហា**

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- លោកឧកញ៉ា **លី ថៃហួ**

២- លោកជំទាវ **ច័ន្ទ វណ្ណា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១១០៥.៥០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

លេខ ៤៤៩ ច.ល
បានដឹងឮចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៥០០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានលុបឈ្មោះឯកឧត្តម **អ៊ុខ ផន** ឧត្តមមន្ត្រីថ្នាក់លេខ ១ ចេញពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១ ដោយមូលហេតុមរណភាព។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៥.៥០៥

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

លេខ: ៤៨១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនរេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៥០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូន ឧត្តមសេនីយ៍ទោ **សៀក សុជាតិ** អត្តលេខ ០០៥២០៨ នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១១០៥.៥០៦

ធ្វើនៅព្រះបរមរាជវាំង ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៤៩៧ ច.ល
សម្រាប់ចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៥០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម ៖

**ក- ថ្នាក់ឧត្តមសេនីយ៍ទោ :**

១- លោកឧត្តមសេនីយ៍ត្រី **ខេង លីដា** អត្តលេខ ០៧៣៤
២- លោកឧត្តមសេនីយ៍ត្រី **ឆាយ សុវណ្ណា** អត្តលេខ ០៧៤៧
៣- លោកឧត្តមសេនីយ៍ត្រី **ជា ឆា** អត្តលេខ ៦៤៤៦៨
៤- លោកឧត្តមសេនីយ៍ត្រី **យន់ ឆៃយ៉ា** អត្តលេខ ០០៨០ ។

**ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី :**

១- លោកវរសេនីយ៍ឯក **ម៉ិញ សុធីវណ្ណ** អត្តលេខ ០៧០២
២- លោកវរសេនីយ៍ឯក **ម៉ៅ ច័ន្ទមធុរិទ្ធ** អត្តលេខ ៥៤០៤៥

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៣- លោកវរសេនីយ៍ឯក ឡោ សុឡេង អត្តលេខ ៥៤២៨០

៤- លោកវរសេនីយ៍ឯក **សាន តាំងស៊ីឡឿន** អត្តលេខ ០៥៤៥៩

៥- លោកវរសេនីយ៍ឯក **ស៊ិន ម៉ិនថន** អត្តលេខ ០២២៨៤

៦- លោកវរសេនីយ៍ឯក **អ៊ុក ចន្ថា** អត្តលេខ ០១០០៦

៧- លោកវរសេនីយ៍ឯក **ហាឲ្យ សុផាណារ៉ា** អត្តលេខ ០៦៩៤

៨- លោកវរសេនីយ៍ឯក **ចាប់ សំផល** អត្តលេខ ០៦៥០

៩- លោកវរសេនីយ៍ឯក **យឹម សុវណ្ណ** អត្តលេខ ០៦៤៤

១០- លោកវរសេនីយ៍ឯក **ជា គឹមហ៊ន** អត្តលេខ ៣០៦០៩

១១- លោកវរសេនីយ៍ឯក **អោម សារ៉ន** អត្តលេខ ០២២៧៨

១២- លោកវរសេនីយ៍ឯក **សេង សារី** អត្តលេខ ០១៥១

១៣- លោកវរសេនីយ៍ឯក **មាស ម៉ារីន** អត្តលេខ ០៣០០

១៤- លោកវរសេនីយ៍ឯក **សឿង អូន** អត្តលេខ ០៦៤០

១៥- លោកវរសេនីយ៍ឯក **កេង សុគន្ធ** អត្តលេខ ០២២៩៧

១៦- លោកវរសេនីយ៍ឯក **ជា ឌុច** អត្តលេខ ០៤១៧

១៧- លោកវរសេនីយ៍ឯក **កើត ប៊ុណ្ណា** អត្តលេខ ០១២៤២

១៨- លោកវរសេនីយ៍ឯក **និត្យ ម៉ិនណា** អត្តលេខ ០៦៩៦

១៩- លោកវរសេនីយ៍ឯក **ឈុន ចាន់សុខា** អត្តលេខ ០៦៩៨

២០- លោកវរសេនីយ៍ឯក **ព្រំ ឌុត្ថា** អត្តលេខ ០១២៦៥

២១- លោកវរសេនីយ៍ឯក **ខៀវ សំណាង** អត្តលេខ ០១៣០៥

២២- លោកវរសេនីយ៍ឯក **សុខ ទ្រេះ** អត្តលេខ ០១៣៧៥ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១*

ពរល. ១១០៥.៥១២

លេខៈ ៤៧២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

(2/2)

ឃុន ជិនកេន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៤ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងមហាផ្ទៃ
- តាមសំណើ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- តាមសំណើ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើ របស់សាលារាជធានីភ្នំពេញ

# សម្រេច

**មាត្រា ១** :-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ រួមមាន ៖

-ទីតាំងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ថិតនៅឡូត៍លេខ ៣ ផ្លូវលេខ ៥៥ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលមានផ្ទៃដីទំហំ ៦៤៦ ម៉ែត្រក្រឡា។

-ទីតាំងសាលាសង្កាត់ចតុមុខ ស្ថិតនៅផ្ទះលេខ ១០ AEO ផ្លូវលេខ ៥៩ សង្កាត់ចតុមុខ ដែលមានផ្ទៃដីទំហំ ៣,៨០ ម៉ែត្រ គុណ ១៤ ម៉ែត្រ។

-ទីតាំងសាលាស្រុកឈូក ស្ថិតនៅភូមិឈើទាល ឃុំឈូក ដែលមានផ្ទៃដីទំហំ ១.២៦០ ម៉ែត្រក្រឡា។

-ទីតាំងអតីតមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តស្ទឹងត្រែង ស្ថិតនៅភូមិថ្មលាត សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដែលមានផ្ទៃដីទំហំ ៦២៩ ម៉ែត្រក្រឡា។

**មាត្រា ២** :-

ការលប់ទីតាំងដូចមានចែងក្នុងមាត្រា ១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាលារាជធានីភ្នំពេញ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣** :-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤** :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០៩ . អនក្រ . បក

# អនុក្រឹត្យ
# ស្តីពី
# យោធិនជាប់កិច្ចសន្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១០/៦៥៥ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១០ ស្តីពីលក្ខន្តិកៈដោយឡែកនៃយោធិនបម្រុង

- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងជ្រើសរើសយោធិនជាប់កិច្ចសន្យា ដើម្បីកសាងប្រភពកម្លាំងនៃកងយោធពលខេមរភូមិន្ទ សម្រាប់បម្រើការងារសេវារដ្ឋបាល ជំនាញឯកទេស ជំនាញបច្ចេកទេស និងប្រតិបត្តិការសឹក។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីចំនួននិងលក្ខខណ្ឌនៃការជ្រើសរើស ឋានន្តរសក្តិ ស្ថានភាពបាត់បង់សុខភាព សមត្ថភាពការងារ និងការហ្វឹកហ្វឺនវិជ្ជាជីវៈ ព្រមទាំងគុណប្រយោជន៍របស់យោធិនជាប់កិច្ចសន្យា ដោយអនុលោមតាមជំពូកទី៦ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះយោធិនជាប់កិច្ចសន្យានៅក្នុងកងយោធពលខេមរភូមិន្ទ។

## ជំពូកទី២
## ចំនួននិងលក្ខខណ្ឌនៃការជ្រើសរើស

**មាត្រា ៤.-**

ចំនួនយោធិនជាប់កិច្ចសន្យា ត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា ៥.-**

យោធិនជាប់កិច្ចសន្យាត្រូវមាន ៖

-សញ្ជាតិខ្មែរ លើកលែងតែក្នុងពេលមានសង្គ្រាម

-អាយុគ្រប់១៨(ដប់ប្រាំបី)ឆ្នាំ

-សម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ។

**មាត្រា ៦._**

កិច្ចសន្យាដំបូងមានរយៈពេល៣(បី) ទៅ៥(ប្រាំ)ឆ្នាំ ហើយអាចបន្តជាដំណាក់ៗ១(មួយ)ឆ្នាំម្តង។

ការសម្រេចឲ្យចូលបម្រើការងារ ក្នុងសេវាយោធិនជាប់កិច្ចសន្យា និងការសម្រេចឲ្យបន្តកិច្ចសន្យាជាថ្មី ព្រមទាំងទម្រង់បែបបទនៃកិច្ចសន្យា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

នាយកដ្ឋានបុគ្គលិក ធ្វើជាសេនាធិការជូនក្រសួងការពារជាតិ ក្នុងការជ្រើសរើសនិងការគ្រប់គ្រងយោធិនជាប់កិច្ចសន្យា។

**មាត្រា ៧._**

យោធិនជាប់កិច្ចសន្យាមានសិទ្ធិ កាតព្វកិច្ច ភារកិច្ច និងវិន័យដូចយោធិនអាជីព ស្របតាមបទប្បញ្ញត្តិទាំងឡាយដូចមានចែងក្នុងជំពូកទី២នៃច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងបទប្បញ្ញត្តិទាំងឡាយ ដូចមានចែងក្នុងអនុក្រឹត្យស្តីពីបទវិន័យទូទៅ សម្រាប់កងយោធពលខេមរភូមិន្ទ។

**មាត្រា ៨._**

យោធិនជាប់កិច្ចសន្យា មិនត្រូវអនុញ្ញាតឲ្យផ្លាស់ប្តូរមុខជំនាញ ផ្ទេរក្របខណ្ឌ ឬស្នើសុំដាក់ឲ្យនៅក្រៅមុខតំណែងឡើយ។

**មាត្រា ៩._**

យោធិនជាប់កិច្ចសន្យា ត្រូវបានបញ្ឈប់ក្នុងករណីណាមួយដូចខាងក្រោម ៖

- អវត្តមានពីការងារក្នុងរយៈពេល១៥(ដប់ប្រាំ) ថ្ងៃជាប់ៗគ្នា ដោយពុំមានមូលហេតុត្រឹមត្រូវ
- មិនគោរពកិច្ចសន្យា
- អសមត្ថភាពសម្បទាវិជ្ជាជីវៈ
- បាត់បង់សុខភាពតាមការវាយតម្លៃរបស់វេជ្ជបណ្ឌិត
- ត្រូវបានតុលាការផ្តន្ទាទោស
- ទទួលមរណភាព។

**មាត្រា ១០._**

កិច្ចសន្យា ត្រូវបញ្ចប់នៅពេលកិច្ចសន្យាផុតកំណត់។ កិច្ចសន្យាអាចបន្តជាថ្មីបានចាប់ពីថ្ងៃចប់កិច្ចសន្យាមុន។

ក្រសួងការពារជាតិ ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ជូនយោធិនដែលបានបញ្ចប់កិច្ចសន្យា។

## ជំពូកទី៣
## ឋានន្តរសក្តិ

**មាត្រា ១១.-**

ការតែងតាំងឋានន្តរសក្តិដំបូងរបស់យោធិនជាប់កិច្ចសន្យា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ យោងតាមសមត្ថភាពជំនាញ ឯកទេស និងវិជ្ជាជីវៈ។

**មាត្រា ១២.-**

ការដំឡើងឋានន្តរសក្តិចំពោះយោធិនជាប់កិច្ចសន្យា ត្រូវអនុវត្តទៅតាមជម្រើស តាមអតីតភាពការងារ និងតាមលក្ខខណ្ឌប្រភេទកងទ័ពឬជំនាញឯកទេស ដូចយោធិនអាជីព។

អតីតភាពនៃយោធិនជាប់កិច្ចសន្យា ត្រូវគិតចាប់តាំងពីថ្ងៃចូលបម្រើការងារ។

**មាត្រា ១៣.-**

យោធិនជាប់កិច្ចសន្យា អាចត្រូវបានតាំងស៊ិបជានាយទាហានរងអាជីពបាន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានអតីតភាពការងារក្នុងសេវាយោធិនជាប់កិច្ចសន្យាយ៉ាងតិច ៤(បួន)ឆ្នាំ និងមានឋានន្តរសក្តិជានាយទាហានរងស្រាប់

-មានសម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ។

## ជំពូកទី៤
## ស្ថានភាពបាត់បង់សុខភាព

**មាត្រា ១៤.-**

យោធិនជាប់កិច្ចសន្យា ដែលបាត់បង់សុខភាពរហូតដល់អសមត្ថភាពសម្បទាវិជ្ជាជីវៈ ត្រូវបានចាត់ទុកថាបាត់បង់សមត្ថភាពការងារ។ ក្នុងករណីនេះ កិច្ចសន្យាត្រូវបានបញ្ឈប់ សាមីយោធិនជាប់កិច្ចសន្យាត្រូវទទួលរបបឧបត្ថម្ភតែម្តងគត់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា ១៥.-**

យោធិនជាប់កិច្ចសន្យាដែលមានជំងឺឬគ្រោះថ្នាក់ផ្សេងៗ ត្រូវទទួលបានការព្យាបាលនៅតាមបណ្តាញប្រព័ន្ធសុខាភិបាលសាធារណៈនិងយោធា។

បើការព្យាបាលជាសះស្បើយក្នុងរយៈពេល៦(ប្រាំមួយ)ខែ សាមីយោធិនត្រូវទទួលឲ្យចូលបម្រើការងារវិញ។

បើការព្យាបាលមានរយៈពេលលើសពី៦(ប្រាំមួយ)ខែ សាមីយោធិនត្រូវដាក់ឲ្យស្ថិតក្នុងស្ថានភាពបាត់បង់សុខភាព ហើយកិច្ចសន្យាត្រូវបានបញ្ចប់។

ចំពោះយោធិនជាប់កិច្ចសន្យាមានជំងឺឬគ្រោះថ្នាក់ផ្សេងៗក្នុងពេលបំពេញការងារ យោធិនទទួលបានការព្យាបាលរហូតដល់ជាសះស្បើយ។

## ជំពូកទី៥
## សមត្ថភាពការងារ

**មាត្រា ១៦.-**

យោធិនជាប់កិច្ចសន្យា ដែលបានបម្រើការងារលើសពី៤(បួន)ឆ្នាំ មានសមត្ថភាពការងារ និងបង្កើតស្នាដៃល្អ មានអាទិភាពទទួលបានការបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសជានាយទាហានអាជីពនៃកងយោធពលខេមរភូមិន្ទ។

## ជំពូកទី៦
## ការហ្វឹកហ្វឺនវិជ្ជាជីវៈ

**មាត្រា ១៧.-**

យោធិនជាប់កិច្ចសន្យា អាចទទួលបានការហ្វឹកហ្វឺនក្បួនខ្នាតយោធានិងការបំប៉នវិជ្ជាជីវៈបន្ថែម នៅតាមសាលាបច្ចេកទេសនានាក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីបង្កើនសមត្ថភាពរបស់ខ្លួន។

## ជំពូកទី៧
## គុណប្រយោជន៍

**មាត្រា ១៨.-**

យោធិនជាប់កិច្ចសន្យា ត្រូវទទួលប្រាក់បៀវត្សរ៍ទៅតាមការកំណត់នៃឋានន្តរសក្តិ និងប្រាក់បំណាច់ប្រចាំខែ ព្រមទាំងការផ្គត់ផ្គង់និងការបំពាក់ដូចយោធិនអាជីព។

**មាត្រា ១៩.-**

យោធិនជាប់កិច្ចសន្យាដែលបានបញ្ចប់កិច្ចសន្យា ទទួលបានរបបឧបត្ថម្ភចេញពីជួរ ដែលស្មើនឹងប្រាក់បៀវត្សរ៍មូលដ្ឋាន តាមឋានន្តរសក្តិយោធិនអាជីពប្រចាំខែចុងក្រោយរបស់សាមីខ្លួនគុណនឹងចំនួនឆ្នាំដែលបានបម្រើការងារកន្លងមក។

**មាត្រា ២០.-**

យោធិនជាប់កិច្ចសន្យាដែលមានស្នាដៃល្អក្នុងការងារ ត្រូវទទួលបានការសរសើរលើកទឹកចិត្តនិងគ្រឿងឥស្សរិយយសដូចយោធិនអាជីព។

**មាត្រា ២១.-**

យោធិនទាំងពីរភេទដែលបានបញ្ចប់កិច្ចសន្យា ត្រូវទទួលបាន ៖

- អាទិភាពក្នុងការជ្រើសរើសឲ្យចូលបម្រើការងារក្នុងស្ថាប័នរដ្ឋ សហគ្រាសសាធារណៈ ឬក្រុមហ៊ុនឯកជននានា តាមជំនាញដែលខ្លួនមាន
- ការរំកិលអាយុតាមចំនួនឆ្នាំដែលបានបម្រើការងារក្នុងសេវាយោធិនជាប់កិច្ចសន្យា សម្រាប់រាល់ការប្រឡងប្រជែងចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ឬចូលក្នុងសហគ្រាសសាធារណៈ ឬក្រុមហ៊ុនឯកជននានា
- ការអនុញ្ញាតឲ្យចូលបម្រើការងារក្នុងក្របខណ្ឌដើមវិញ ដោយទទួលបានអាទិភាពក្នុងការដំឡើងថ្នាក់ ឋានន្តរសក្តិ ឋានៈ ឬតួនាទី។

រយៈពេលបម្រើការងារក្នុងសេវាយោធិនជាប់កិច្ចសន្យា ត្រូវបានរាប់បញ្ចូលក្នុងអតីតភាពសម្រាប់ការចូលនិវត្តន៍ ក្នុងករណីដែលយោធិនជាប់កិច្ចសន្យាបានចូលក្នុងក្របខណ្ឌយោធិនអាជីព ឬបានចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល។

**មាត្រា ២២.-**

យោធិនជាប់កិច្ចសន្យានិងគ្រួសារក្នុងបន្ទុក មានសិទ្ធិទទួលបានការព្យាបាលជំងឺនៅតាមបណ្តាញសុខាភិបាលយោធា។

ក្នុងករណីពលី មរណៈ ឬពិការ យោធិនជាប់កិច្ចសន្យា ត្រូវទទួលបានរបបឧបត្ថម្ភដូចយោធិនអាជីព។

ការបាត់ខ្លួនក្នុងពេលបំពេញបេសកកម្មឬពេលមានសង្គ្រាមរបស់យោធិនជាប់កិច្ចសន្យា ត្រូវដាក់ឲ្យស្ថិតនៅក្នុងសេវាយោធិនជាប់កិច្ចសន្យារហូតដល់ពេលមានវត្តមានឬពេលមានការចង្អុលភស្តុតាងអំពីមរណភាព។

**មាត្រា ២៣.-**

យោធិនដែលបានបញ្ចប់កិច្ចសន្យា ត្រូវទទួលបានរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា ២៤.-**

កិច្ចសន្យាឲ្យចូលបម្រើការងារក្នុងកងយោធពលខេមរភូមិន្ទ ដែលមិនស្របទៅតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវរៀបចំសាជាថ្មី។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ១១០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ , ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១** : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៥០០ លានរៀល ( ប្រាំរយលានរៀលគត់ ) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) ជូនក្រសួងធនធានទឹក និង ឧតុនិយម សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ផ្តល់ជូនអាជ្ញាធរទន្លេសាប ចំណាយលើការងារបោះបង្គោលកំណត់តំបន់ព្រៃលិចទឹក និងការរំលាយ-កែសម្រួលបណ្តាអាងទឹក ដែលបានសាងសង់ឡើងនៅជុំវិញបឹងទន្លេសាប។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយមត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងនិរាករណ៍អនុក្រឹត្យ លេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ ប្រើប្រាស់ដោយចីរភាព
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## សម្រេច

**មាត្រា១ៈ**

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិចំនួនពីរ(០២)កន្លែង ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់ផ្តល់ជូនក្រុមហ៊ុនចំនួន០២ ធ្វើការវិនិយោគ និងអភិវឌ្ឍន៍ស្របតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ រួមមានៈ

ក. ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ លើផ្ទៃដីចំនួន **៩.០៥៩ហិកតា(ប្រាំបួនពាន់ ហាសិបប្រាំបួនហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ហ្គោត ហៀល (ខេមបូឌា) អ៊ិនធឺណាស្យូណាល់ លីមីធីត** ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៦១៦ សជណ.កស ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

ខ. ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ លើផ្ទៃដីចំនួន **៨.៥៩១ហិកតា(ប្រាំបីពាន់ ប្រាំរយ កៅសិបមួយហិកតា)** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ក្នុងភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **យេលឡូ ហៀល (ខេមបូឌា) អ៊ិនធឺណាស្យូណាល់ លីមីធីត** ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៦១៦ សជណ.កស ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមិថុនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីទីតាំងដីវិនិយោគ អភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន Yellow Field ( Cambodia ) International Limited

ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ឃុំមិសាស្ត្រ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ លើផ្ទៃដី ៨៥៩១ ហិកតា




| ID | N | X | Y |
|---|---|---|---|
| 1 | A | 378031 | 1287985 |
| 2 | B | 380048 | 1287997 |
| 3 | C | 381606 | 1288006 |
| 4 | D | 381602 | 1290644 |
| 5 | E | 383424 | 1290643 |
| 6 | F | 384435 | 1290642 |
| 7 | G | 387048 | 1289125 |
| 8 | H | 387416 | 1287451 |
| 9 | I | 387365 | 1286169 |
| 10 | J | 389178 | 1285917 |
| 11 | K | 389953 | 1284362 |
| 12 | L | 390381 | 1282640 |
| 13 | M | 392948 | 1281274 |
| 14 | N | 392570 | 1279820 |
| 15 | O | 391147 | 1279338 |
| 16 | P | 389878 | 1278418 |
| 17 | Q | 388595 | 1277536 |
| 18 | R | 387904 | 1277731 |
| 19 | S | 386205 | 1278711 |
| 20 | T | 384871 | 1280098 |
| 21 | U | 383919 | 1281722 |
| 22 | V | 383180 | 1283574 |
| 23 | W | 381998 | 1285134 |
| 24 | X | 380203 | 1285941 |
| 25 | Y | 378810 | 1287271 |
| 26 | Z | 392522 | 1281747 |
| 27 | A1 | 392469 | 1283715 |
| 28 | B2 | 385304 | 1289392 |

**សញ្ញាសំគាល់**

Coordinate System

ហ្វាស់ លាស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៥២ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលមាត្រា ១៣ និងមាត្រា ៣០ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និងការកែសម្រួលមាត្រា ១១ថ្មី នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលមាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៥ និងមាត្រា ១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## **សម្រេច**

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដូចមានរាយមានខាងក្រោម÷

១. លោក **លី ឧុទ្ធី** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានកិច្ចការទូទៅ

២. លោក **ហ៊ាន ម៉ុនណិត** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងព័ត៌មាន។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៥៣-អនក្រ-បក

## អនុក្រឹត្យ

### ស្តីពីការតែងតាំងមុខងារ នាយទាហាន

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃ កងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-ឧត្តមសេនីយ៍ទោ **ចាប តក្កី** អត្តលេខ ០០០៨៣០ ជា នាយរងសេនាធិការចំរុះ និងជា មេបញ្ជាការកងពលតូចទ័ពពិសេសឆ័ត្រយោង៩១១ អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ទោ **ព្រហ្ម ផេង** អត្តលេខ ០០០៤២៨ ជា នាយរងសេនាធិការចំរុះ និងជា មេបញ្ជាការកងពលតូចអន្តរាគមន៍លេខ១ អគ្គបញ្ជាការដ្ឋាន

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង បណ្តា សមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៥៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ អាណត្តិទី ៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩៩ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតធនាគារអភិវឌ្ឍន៍ជនបទ
- បានឃើញលក្ខន្តិកៈ នៃធនាគារអភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ៣២២ អនក្រ.តត ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ ស្តីពីការតែងតាំងប្រធានអគ្គនាយករបស់ធនាគារអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ និងអនុក្រឹត្យលេខ ១០២៦ អនក្រ.តត ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១.-** ត្រូវបានតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ អាណត្តិទី ៥ ចំនួន ០៥ រូប ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ២-លោក **ហ៊ែល ចំរើន** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៣-លោក **លី សាវុធ** | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៤-លោក **អ៊ូ សុផាណារិទ្ធ** | តំណាងអាជីវករក្នុងវិស័យធនាគារ | ជាសមាជិក |
| ៥-លោកជំទាវឧកញ៉ា **តាន់ ផល្លី** | តំណាងស្ថាប័នមីក្រូហិរញ្ញវត្ថុ | ជាសមាជិក |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបញ្ចប់មុខតំណែងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី

